ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

ក្រសួងពាណិជ្ជកម្ម

លេខ : ០៤១ កយ.ពណ.ប្រក/២៣

# ប្រកាសអន្តរក្រសួង
## ស្តីពី
## នីតិវិធីនៃការផាកពិន័យជាប្រាក់ លើអំពើល្មើសនឹងច្បាប់ស្តីពីការប្រកួតប្រជែង

រដ្ឋមន្ត្រី
ក្រសួងយុត្តិធម៌

រដ្ឋមន្ត្រី
ក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០២១/០១៣ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រកួតប្រជែង
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣០ អនក្រ.បក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

## សម្រេច

**ប្រការ១.-**

ប្រកាសអន្តរក្រសួងនេះ កំណត់អំពីនីតិវិធីនៃការផាកពិន័យជាប្រាក់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង។

**ប្រការ២.-**

ប្រកាសអន្តរក្រសួងនេះ មានវិសាលភាពអនុវត្តចំពោះការផាកពិន័យជាប្រាក់លើអំពើល្មើសដែលមានចែងក្នុងមាត្រា៣៥ នៃច្បាប់ស្តីពីការប្រកួតប្រជែង។

**ប្រការ៣.-**

គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «**គ.ប.ក.**» មានសមត្ថកិច្ចធ្វើការសម្រេចផាកពិន័យជាប្រាក់ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការប្រកួតប្រជែង។

អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្រ្កាបការក្លែងបន្លំ «ក.ប.ប.» នៃក្រសួងពាណិជ្ជកម្ម ជាសេនាធិការរបស់ **គ.ប.ក.** ត្រូវទទួលបន្ទុកអនុវត្តនីតិវិធីពាក់ព័ន្ធនឹងការផាកពិន័យជាប្រាក់ចំពោះបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីការប្រកួតប្រជែង។

**ប្រការ៤.-**

មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ មានភារកិច្ចដូចតទៅ៖

- ធ្វើកំណត់ហេតុបទល្មើសនៃការផាកពិន័យជាប្រាក់
- ចេញកំណត់ត្រាស្តីពីបណ្ណផាកពិន័យជាប្រាក់
- ចេញវិក្កយបត្របង់ប្រាក់ផាកពិន័យ ស្របតាមការកំណត់នៅក្នុងសេចក្តីសម្រេចស្តីពីការផាកពិន័យរបស់ **គ.ប.ក.**
- ទទួលប្រាក់ផាកពិន័យ និងចេញបង្កាន់ដៃបង់ប្រាក់ឱ្យបុគ្គលប្រព្រឹត្តល្មើស ក្នុងករណីទទួលប្រាក់ផាកពិន័យ ដោយផ្ទាល់ជាសាច់ប្រាក់ ជាមូលប្បទានបត្រ ឬតាមមធ្យោបាយផ្សេងទៀត
- ចេញលិខិតជូនដំណឹងក្រើនរំលឹកចំពោះបុគ្គលប្រព្រឹត្តល្មើស ឱ្យមកបង់ប្រាក់ផាកពិន័យមិនឱ្យហួសកាលបរិច្ឆេទចុងក្រោយនៃការបង់ប្រាក់ផាកពិន័យ
- ធ្វើរបាយការណ៍ពាក់ព័ន្ធនឹងការបង់ប្រាក់ផាកពិន័យ ជូន **គ.ប.ក.**
- កសាងសំណុំរឿងតាមនីតិវិធីច្បាប់ជាធរមានទៅតុលាការមានសមត្ថកិច្ច ក្នុងករណីបុគ្គលប្រព្រឹត្តល្មើសមិនបានបង់ប្រាក់ផាកពិន័យ ដោយអនុលោមតាមនីតិវិធីដូចមានចែងក្នុងប្រការ៦នៃប្រកាសនេះ។

**ប្រការ៥.-**

បុគ្គលប្រព្រឹត្តល្មើស ត្រូវបង់ប្រាក់ផាកពិន័យជូនមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ភ្លាមៗ ឬយ៉ាងយូរ៣០(សាមសិប)ថ្ងៃ ឬតាមការសម្រេចផ្សេងពីនេះដោយ **គ.ប.ក.** គិតចាប់ពីថ្ងៃដែលសាមីខ្លួនទទួលបានឯកសារពាក់ព័ន្ធនឹងការផាកពិន័យជាប្រាក់ ពីមន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.**។

ក្នុងករណីបុគ្គលប្រព្រឹត្តល្មើសមិនបានបង់ប្រាក់ផាកពិន័យ និងមិនបានដាក់ពាក្យបណ្ដឹងតវ៉ានៅក្នុងរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី១នៃប្រការ៧នៃប្រកាសនេះ មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវរាយការណ៍ជូន **គ.ប.ក.** និងស្នើសុំ **គ.ប.ក.** ដើម្បីកសាងសំណុំរឿងតាមនីតិវិធីជាធរមានទៅតុលាការមានសមត្ថកិច្ច។

**ប្រការ៦ ._**

មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវបញ្ជូនលិខិតជូនដំណឹង និងឯកសារពាក់ព័ន្ធនឹងការផាកពិន័យជាប្រាក់ទៅគេហដ្ឋាន ទីស្នាក់ការ ឬទីតាំងនៃការធ្វើធុរកិច្ចដោយផ្ទាល់ ឬតាមសំបុត្រអនុសិដ្ឋដោយមានចុះហត្ថលេខាបានទទួល។

ក្នុងករណីដែលបុគ្គលប្រព្រឹត្តល្មើសបដិសេធមិនព្រមទទួលលិខិតជូនដំណឹង និងឯកសារពាក់ព័ន្ធនឹងការផាកពិន័យជាប្រាក់ ឬមិនមានម្ចាស់ឬតំណាងទទួលលិខិតជូនដំណឹង មន្ត្រីស៊ើបអង្កេតនៃអគ្គនាយកដ្ឋាន **ក.ប.ប.** ត្រូវបិទសេចក្ដីជូនដំណឹងពីការផាកពិន័យនៅគេហដ្ឋាន ទីស្នាក់ការ ឬទីតាំងនៃការធ្វើធុរកិច្ច និងនៅសាលាឃុំ សង្កាត់។ បន្ទាប់ពីបានបិទផ្សាយរួច ឯកសារទាំងនោះត្រូវចាត់ទុកថាបានទទួលជាផ្លូវការដោយបុគ្គលប្រព្រឹត្តល្មើស។

**ប្រការ៧ ._**

បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ **គ.ប.ក.** មានសិទ្ធិប្ដឹងតវ៉ាទៅ **គ.ប.ក.** ឱ្យពិនិត្យនិងសម្រេចឡើងវិញ ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេចរបស់ **គ.ប.ក.**។ **គ.ប.ក.** ត្រូវសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ដោយគិតចាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹងតវ៉ានោះ។

បុគ្គលណាមួយដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ **គ.ប.ក.** មានសិទ្ធិប្ដឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ដោយគិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេចរបស់ **គ.ប.ក.**។

**ប្រការ៨ ._**

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈឱ្យបានទូលំទូលាយនូវខ្លឹមសារប្រកាសអន្តរក្រសួងនេះ និងត្រូវរៀបចំឱ្យមានកន្លែងទទួលពាក្យបណ្ដឹងតវ៉ា ឬការមិនសុខចិត្តណាមួយ ចំពោះការផាកពិន័យជាប្រាក់ដែលកំណត់ដោយ **គ.ប.ក.**។

**ប្រការ៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ .-**

សមាសភាពគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៤កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**
**ក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**រដ្ឋមន្ត្រី**
**ក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ